**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយសាលានគរបាលជាតិជីឥវ៉ូ ទៅជាសាលាមធ្យមវិជ្ជាជីវៈនគរបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលនាយកដ្ឋានបណ្តុះបណ្តាលនិង វិក្រឹតការ នៃក្រសួងមហាផ្ទៃ
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ៈ**

ត្រូវបានប្រែក្លាយសាលានគរបាលជាតិជីឥវ៉ូនៃនាយកដ្ឋានបណ្តុះបណ្តាល ទៅជាសាលាមធ្យមវិជ្ជាជីវៈនគរបាល សរសេរកាត់ "សមវន" ។ សាលាមធ្យមវិជ្ជាជីវៈនគរបាល មានទីតាំងស្ថិត នៅ ភូមិទីមួយ

www.pheakdeylaw.com

ឃុំត្រែងត្រយឹង ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ ។

**មាត្រា២:-**

សាលាមធ្យមវិជ្ជាជីវៈនគរបាល មានឋានៈស្មើ នាយកដ្ឋាន និង ស្ថិតនៅចំណុះ បណ្ឌិត្យសភានគរបាលកម្ពុជា ។ សាលាមធ្យមវិជ្ជាជីវៈនគរបាល ដឹកនាំដោយនាយក មួយរូប និង នាយករងមួយចំនួនជាជំនួយ តាមការចាំបាច់ ។

**មាត្រា៣:-**

សាលាមធ្យមវិជ្ជាជីវៈនគរបាល ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល ដល់សិស្ស និស្សិត កម្រិតមធ្យមវិជ្ជាជីវៈនគរបាល( បរិញ្ញាបត្ររងវិជ្ជាជីវៈនគរបាល) និង ធ្វើវិក្រឹតការ សុក្រឹតការជំនាញឯកទេសជូនមន្ត្រីនគរបាលជាតិ ។

សាលាមធ្យមវិជ្ជាជីវៈនគរបាល ត្រូវរៀបចំកម្មវិធីសិក្សាកម្រិតមធ្យមវិជ្ជាជីវៈនគរបាល ដោយមានការឯកភាពពី បណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ និង មានការទទួល ស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៤:-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សាកម្រិតមធ្យមវិជ្ជាជីវៈនគរបាល នៅសាលាមធ្យមវិជ្ជាជីវៈនគរបាល និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រ មធ្យមវិជ្ជាជីវៈនគរបាល តាមមុខជំនាញឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ នឹងចុះហត្ថលេខាដោយ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៥:-**

លក្ខខណ្ឌនៃការជ្រើសរើសសិស្ស និស្សិត ឱ្យចូលរៀនថ្នាក់មធ្យមវិជ្ជាជីវៈនគរបាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ដោយអនុលោមទៅតាម បទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៦:-**

សាលាមធ្យមវិជ្ជាជីវៈនគរបាលមានភារកិច្ច ដូចតទៅ :

- រៀបចំផែនការបណ្តុះបណ្តាលកងកំលាំងនគរបាលជាតិ សម្រាប់កម្រិត មធ្យមវិជ្ជាជីវៈនគរបាល
- រៀបចំផែនការ និងកម្មវិធី វិក្រឹតការ សុក្រឹតការមុខជំនាញឯកទេសដល់មន្ត្រីនគរបាលជាតិ

www.pheakdeylaw.com

- សិក្សាស្រាវជ្រាវធ្វើទំនើបភាវូបនីយកម្មខ្លឹមសារបង្ហាត់បង្រៀន កម្មវិធីសិក្សា និង កម្មសិក្សាប្រតិបត្តិ
- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាល ក្នុងការរៀបចំគម្រោងផែនការថវិកា សម្ភារៈ បរិក្ខារ មធ្យោបាយ សម្រាប់កិច្ចដំណើរការរបស់សាលាមធ្យមវិជ្ជាជីវៈនគរបាល
- ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនកម្មសិក្សាការីដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ
- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ គណនេយ្យ របស់សាលាមធ្យមវិជ្ជាជីវៈនគរបាល
- ធ្វើរបាយការណ៍តាមការកំណត់ជូនបណ្ឌិត្យសភានគរបាលកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឱ្យ ។

**មាត្រា៧ៈ-**

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ចអង្គភាពចំណុះសាលាមធ្យមវិជ្ជាជីវៈនគរបាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៨ៈ-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩ៈ-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៩*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com